ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# កម្រងឯកសារគោល
# នៃការរៀបចំក្របខ័ណ្ឌស្ថាប័នពាក់ព័ន្ធនឹង
# ការប្រឆាំងការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម
# និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ

២០២០

# អនុក្រឹត្យ
# ស្តីពី
# ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការ
# សម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និង
# ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទាន
# ដល់ការរីកសាយភាយអាវុធមហាប្រល័យ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៦០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិ ប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦២០/០២១ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦២០/០១៩ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយអាវុធមហាប្រល័យ
- បានឃើញអនុក្រឹត្យលេខ១៤២ អនក្រ.បក ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅនៃ**គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងការរីកសាយភាយអាវុធមហាប្រល័យ**ហៅកាត់ថាគ.ស.ហ.ដែលជាយន្តការសម្របសម្រួលជាន់ខ្ពស់ ក្នុងការអនុវត្តច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។

## ជំពូកទី២
## សមាសភាព

**មាត្រា២ .-**

គ.ស.ហ. មានសមាសភាពដូចតទៅ៖

| | |
|---|---|
| - ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | ប្រធាន |
| - អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា | អនុប្រធានប្រចាំការ |
| - តំណាងក្រសួងមហាផ្ទៃ | អនុប្រធាន |
| - តំណាងក្រសួងយុត្តិធម៌ | អនុប្រធាន |
| - តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| - តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| - តំណាងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| - តំណាងក្រសួងការពារជាតិ | សមាជិក |
| - តំណាងក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| - តំណាងក្រសួងពាណិជ្ជកម្ម | សមាជិក |
| - តំណាងគណៈកម្មាធិការជាតិប្រឆាំងអំពើភេរវកម្ម | សមាជិក |
| - ប្រធានក្រុមប្រឹក្សាភិបាល នៃអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា | សមាជិក |
| - ប្រធានអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា | លេខាធិការ។ |

សមាសភាពជាក់ស្តែងនៃគ.ស.ហ. ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលតាមសំណើរបស់ប្រធានគ.ស.ហ.។

## ជំពូកទី៣
## តួនាទីនិងភារកិច្ច

**មាត្រា៣ .-**

គ.ស.ហ. មានតួនាទី និងភារកិច្ច ដូចខាងក្រោម ៖

១-បង្កើតគោលនយោបាយជាតិ យុទ្ធសាស្ត្រជាតិ យន្តការសម្របសម្រួលអនុវត្តការងារនិងវាយតម្លៃហានិភ័យពាក់ព័ន្ធនឹងការប្រឆាំងកិច្ចការសម្អាតប្រាក់ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។

២-ដឹកនាំនិងសម្របសម្រួលការអនុវត្តច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។

៣-សម្របសម្រួលការអភិវឌ្ឍប្រព័ន្ធប្រឆាំងការសម្អាតប្រាក់ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។

៤-ពិនិត្យអំពីប្រសិទ្ធភាពនិងវឌ្ឍនភាពនៃការអនុវត្តច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ព្រមទាំងបទប្បញ្ញត្តិពាក់ព័ន្ធ។

៥-តាមដាននិងវាយតម្លៃហានិភ័យពាក់ព័ន្ធនឹងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។

៦-ធានាសង្គតិភាពលើគោលការណ៍និងសេចក្តីណែនាំ និងការបណ្តុះបណ្តាលរបស់ក្រសួង ស្ថាប័នត្រួតពិនិត្យពាក់ព័ន្ធនឹងការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។

៧-ធានាថាប្រទេសកម្ពុជាប្រតិបត្តិតាមស្តង់ដាតំបន់និងសកលលោកជាអាទិ៍៖

- សេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ
- អនុសាសន៍របស់ក្រុមការងារហិរញ្ញវត្ថុ ( Financial Action Task Force )
- កាតព្វកិច្ចជាសមាជិករបស់ក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិក ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ និងអនុសញ្ញា សេចក្តីសម្រេចចិត្ត សេចក្តីប្រកាស និងផែនការសកម្មភាពការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ របស់អង្គការអន្តរជាតិ។

៨-បង្កើតយន្តការអន្តរក្រសួង ស្ថាប័នតាមការចាំបាច់ដើម្បីអនុវត្តការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។

## ជំពូកទី៤
## កិច្ចដំណើរការងារ

**មាត្រា៤ .-**

គ.ស.ហ. ត្រូវជួបប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬអនុប្រធាន ដោយមានការប្រគល់សិទ្ធិពីប្រធាន។

គ.ស.ហ. ប្រើប្រាស់ត្រារបស់ក្រសួងមហាផ្ទៃ នៅក្នុងការបំពេញការងាររបស់ខ្លួន។

**មាត្រា៥ .-**

គ.ស.ហ. មានសិទ្ធិអញ្ជើញថ្នាក់ដឹកនាំ មន្ត្រីជាន់ខ្ពស់ ឬតំណាងនៃក្រសួង ស្ថាប័នពាក់ព័ន្ធ ឬឥស្សរជន ឬភាគីពាក់ព័ន្ធជាតិនិងអន្តរជាតិនានា ដើម្បីចូលរួមពិភាក្សានិងផ្តល់យោបល់ក្នុងកិច្ចប្រជុំរបស់ គ.ស.ហ. តាមការចាំបាច់។

**មាត្រា៦ .-**

គ.ស.ហ. មានសិទ្ធិបង្កើតអនុគណៈកម្មាធិការ ឬក្រុមការងារមួយ ឬច្រើន ដើម្បីជួយ គ.ស.ហ. បំពេញភារកិច្ចតាមដានវាយតម្លៃនិងសម្របសម្រួលការងារប្រឆាំងការសម្អាតប្រាក់ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។ សមាជិកទាំងនោះអាចត្រូវបានជ្រើសរើសចេញពីក្រសួង ស្ថាប័នតំណាងនៅក្នុង គ.ស.ហ. និងក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀតតាមការចាំបាច់។

**មាត្រា៧ .-**

គ.ស.ហ. មានអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ជាលេខាធិការដ្ឋានសម្រាប់គាំទ្រដល់ការបំពេញតួនាទីនិងភារកិច្ចរបស់ខ្លួន។

តួនាទី ភារកិច្ច និងរបៀបរបបការងាររបស់លេខាធិការដ្ឋានត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន គ.ស.ហ.។

**មាត្រា៨ .-**

ការចំណាយលើការបំពេញតួនាទី ភារកិច្ច និងកិច្ចដំណើរការការងាររបស់ គ.ស.ហ. ត្រូវប្រើប្រាស់កញ្ចប់ថវិការបស់ធនាគារជាតិនៃកម្ពុជា។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា៩ .-**

អនុក្រឹត្យនេះ ត្រូវជំនួសអនុក្រឹត្យលេខ១៧៨ អនក្រ.បក ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលមាត្រា១ នៃអនុក្រឹត្យលេខ៧៩ អនក្រ.បក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការបង្កើតគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងអនុក្រឹត្យលេខ៧៩ អនក្រ.បក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការបង្កើតគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១០ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ១៣ កើត ខែ អស្សុជ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល៖</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ក្រុមប្រឹក្សាភិបាលអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា

# ក្រុមប្រឹក្សាភិបាលនៃអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា

ច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដែលប្រកាសឱ្យប្រើនៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០ បានកំណត់ពីការបង្កើត និងមុខងារ-ភារកិច្ចរបស់ក្រុមប្រឹក្សាភិបាលដូចមានក្នុង មាត្រា១៩ និងមាត្រា២០។ មាត្រា១៩ ចែងអំពីស្ថាប័នប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម រួមមាន ក្រុមប្រឹក្សាភិបាល និងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ហើយមាត្រា២០ បានបង្កើត ក្រុមប្រឹក្សាភិបាល ដែលមានតួនាទីពិគ្រោះយោបល់ និងផ្តល់អនុសាសន៍លើការងារប្រឆាំងការ សម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។

សមាជិកក្រុមប្រឹក្សាភិបាលជាមន្ត្រីជាន់ខ្ពស់តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា និងប្រធានអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ជាលេខាធិការ។

សមាសភាពក្រុមប្រឹក្សាភិបាលជាក់ស្តែងកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់ធនាគារជាតិនៃកម្ពុជា។

## ក្រុមប្រឹក្សាភិបាល

| | | | | | |
|---|---|---|---|---|---|
| | | | | | ប្រធាន<br>អង្គភាពស៊ើបការណ៍<br>ហិរញ្ញវត្ថុកម្ពុជា |
| ទីស្តីការគណៈរដ្ឋមន្ត្រី | ក្រសួងយុត្តិធម៌ | ក្រសួងមហាផ្ទៃ | ក្រសួងសេដ្ឋកិច្ចនិង<br>ហិរញ្ញវត្ថុ | ធនាគារជាតិនៃកម្ពុជា | ជាលេខាធិការ |

# អនុក្រឹត្យ
# ស្តីពី
# ការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពសេវាការណ៍ហិរញ្ញវត្ថុកម្ពុជា

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៤៧ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា១៤ និងមាត្រា៥៧ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦២០/០១៩ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦២០/០២១ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- យោងតាមសំណើរបស់ទេសាភិបាលធនាគារជាតិនៃកម្ពុជា

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ដែលស្ថិតក្រោមធនាគារជាតិនៃកម្ពុជា តទៅនេះហៅកាត់ថា «ស.ហ.ក»។

## ជំពូកទី២
## តួនាទីនិងភារកិច្ចរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា

**មាត្រា២ .-**

ស.ហ.ក មានតួនាទីនិងភារកិច្ចដូចខាងក្រោមៈ

- ទទួលរបាយការណ៍ប្រតិបត្តិការសង្ស័យ ប្រតិបត្តិការសាច់ប្រាក់ និងព័ត៌មានស្តីពីការសង្ស័យនៃការសម្អាតប្រាក់ ឬ ហិរញ្ញប្បទានភេរវកម្ម ដែលត្រូវបានផ្ញើមក
- ប្រមូលព័ត៌មានដែលអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាយល់ថាទាក់ទងដល់សកម្មភាពរបស់ខ្លួនស្តីពីការសម្អាតប្រាក់ ឬហិរញ្ញប្បទានភេរវកម្ម ហើយដែលមានផ្សព្វផ្សាយជាសាធារណៈ រួមមាន ទិន្នន័យពាណិជ្ជកម្ម ក៏ដូចជាព័ត៌មានផ្សេងៗទៀត ដែលចាំបាច់សម្រាប់អនុវត្តមុខងាររបស់ខ្លួន ដូចជា ព័ត៌មានដែលបានប្រមូល និងថែរក្សាទុកក្នុងទិន្នន័យដោយបុគ្គលរាយការណ៍
- យកតាមកាលានុវត្តស្របតាមច្បាប់នូវព័ត៌មានហិរញ្ញវត្ថុ រដ្ឋបាល និងព័ត៌មានសម្រាប់ការពង្រឹងការអនុវត្តច្បាប់ ដែលចាំបាច់សម្រាប់ការបំពេញមុខងាររបស់ខ្លួន រួមទាំងព័ត៌មានដែលត្រូវបានប្រមូល និងថែរក្សាទុកក្នុងទិន្នន័យរបស់ក្រសួង-ស្ថាប័នសាធារណៈផ្សេងៗ
- វិភាគ និង វាយតម្លៃនូវរាល់របាយការណ៍ប្រតិបត្តិការសង្ស័យ និងព័ត៌មានពាក់ព័ន្ធ ដើម្បីកំណត់ពីមូលដ្ឋានសមស្រប ដែលនាំឱ្យជឿជាក់ថាបទល្មើសសម្អាតប្រាក់ ឬបទល្មើសហិរញ្ញប្បទានភេរវកម្មបានកើតឡើង ហើយក្នុងករណីនេះ ត្រូវបញ្ជូនសំណុំរឿងទៅក្រសួង-ស្ថាប័នអនុវត្តច្បាប់ដើម្បីស៊ើបអង្កេតពីបទល្មើស
- ចងក្រងស្ថិតិ និងកត់ត្រាអំពីរបាយការណ៍ប្រតិបត្តិការសង្ស័យនិងសាច់ប្រាក់ ដែលបានទទួលវិភាគ និងបញ្ជូនទៅក្រសួង-ស្ថាប័នអនុវត្តច្បាប់ និងផ្តល់ព័ត៌មានទាំងនោះទៅក្រសួង-ស្ថាប័នសាធារណៈផ្សេងទៀត យោងតាមរឿងហេតុដែលពាក់ព័ន្ធ
- ផ្តល់មតិទៅបុគ្គលរាយការណ៍ និងក្រសួង-ស្ថាប័នពាក់ព័ន្ធផ្សេងៗ នូវលទ្ធផលនៃរបាយការណ៍ប្រតិបត្តិការសង្ស័យ ឬព័ត៌មានផ្សេងៗ
- ធានាថារាល់ព័ត៌មានផ្ទាល់ខ្លួនដែលស្ថិតក្នុងដៃរបស់ខ្លួន ត្រូវបានការពារមិនឱ្យបើកចំហដោយគ្មានការអនុញ្ញាត
- ចេញសេចក្តីណែនាំទៅបុគ្គលរាយការណ៍ស្តីពីការសម្គាល់អត្តសញ្ញាណរបស់អតិថិជន ការរក្សាទុកឯកសារកត់ត្រា ការរាយការណ៍ប្រតិបត្តិការសង្ស័យ និងកាតព្វកិច្ចផ្សេងទៀត
- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃអំពីការអនុវត្តតាមកាតព្វកិច្ច និងប្រតិបត្តិការ របស់បុគ្គលរាយការណ៍ តាមរយៈការត្រួតពិនិត្យលើឯកសារ ការត្រួតពិនិត្យដល់ទីកន្លែង និងវិធានការផ្សេងៗទៀតស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន
- ចេញសេចក្តីណែនាំឱ្យចាត់វិធានការកែតម្រូវនិង/ឬលើកសំណើដាក់ទណ្ឌកម្មចំពោះបុគ្គលរាយការណ៍ ដែលមិនបំពេញតាមកាតព្វកិច្ចរបស់ខ្លួន

- ដាក់ទណ្ឌកម្មខាងរដ្ឋបាល
- សម្របសម្រួល និងបង្កើតយន្តការកិច្ចសហប្រតិបត្តិការថ្នាក់ជាតិ និងអន្តរជាតិ
- តំណាងប្រទេសកម្ពុជាក្នុងព្រឹត្តិការណ៍អន្តរជាតិនានា ដែលជាប់ទាក់ទងនឹងការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- ចាត់វិធានការដើម្បី អប់រំ បណ្តុះបណ្តាល និង/ឬលើកកម្ពស់ការយល់ដឹងដល់បុគ្គលរាយការណ៍ អង្គភាពស្ថាប័នពាក់ព័ន្ធនានា និងសាធារណជន ទាក់ទងនឹងការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការចាំបាច់។

## ជំពូកទី៣
## រចនាសម្ព័ន្ធនិងការគ្រប់គ្រង

**មាត្រា៣ .-**

ស.ហ.ក ត្រូវគ្រប់គ្រង និងចាត់ចែងដោយប្រធានមួយរូប និងអនុប្រធានមួយចំនួន ជាជំនួយការតាមការចាំបាច់។

**មាត្រា៤ .-**

ស.ហ.ក មានរចនាសម្ព័ន្ធដូចតទៅៈ

- នាយកដ្ឋានកិច្ចការផ្ទៃក្នុង
- នាយកដ្ឋានវិភាគ
- នាយកដ្ឋានត្រួតពិនិត្យការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- នាយកដ្ឋានសហប្រតិបត្តិការ
- នាយកដ្ឋាននីតិកម្មនិងបណ្តុះបណ្តាល។

**មាត្រា៥ .-**

នាយកដ្ឋាននីមួយៗត្រូវដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយឬច្រើនរូប តាមការចាំបាច់។

រចនាសម្ព័ន្ធរបស់ ស.ហ.ក ត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា៦ .-**

ការរៀបចំនិងការប្រព្រឹត្តទៅនៃការិយាល័យក្រោមឱវាទរបស់នាយកដ្ឋាននីមួយៗ ត្រូវកំណត់ដោយប្រកាសរបស់ធនាគារជាតិនៃកម្ពុជា។

## ជំពូកទី៤
## តួនាទីនិងភារកិច្ចរបស់នាយកដ្ឋាន

**មាត្រា៧ .-**

នាយកដ្ឋានកិច្ចការផ្ទៃក្នុង មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងកិច្ចការរដ្ឋបាល និងលិខិតស្នាមនានា
- រៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់ ស.ហ.ក
- គ្រប់គ្រងសម្ភារបរិក្ខារការិយាល័យ និងបញ្ជីសារពើភណ្ឌ ទ្រព្យសម្បត្តិរបស់ ស.ហ.ក
- សម្របសម្រួលការផ្ដល់សេវាបច្ចេកវិទ្យាព័ត៌មានវិទ្យា
- រៀបចំ និងបូកសរុបរបាយការណ៍ការងារ
- ចូលរួមសម្របសម្រួលការងាររបស់ក្រុមប្រឹក្សាភិបាល ស.ហ.ក និងគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិ
- ចាត់ចែងការងារទំនាក់ទំនងទូទៅជាមួយភាគីពាក់ព័ន្ធ
- ចាត់ចែងការងារពិធីការទូទៅ
- រៀបចំកិច្ចប្រជុំ សិក្ខាសាលា វគ្គបណ្ដុះបណ្ដាល ផ្សព្វផ្សាយ និងកម្មវិធីផ្សេងៗ
- រៀបចំបោះផ្សាយព័ត៌មាន អំពីការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- រៀបចំផែនការ និងតាមដានការងារពាក់ព័ន្ធនឹងកិច្ចការផ្ទៃក្នុង
- បំពេញការងារផ្សេងៗ ដែលថ្នាក់ដឹកនាំប្រគល់ជូន។

**មាត្រា៨ .-**

នាយកដ្ឋានវិភាគ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ទទួលរបាយការណ៍ប្រតិបត្តិការសង្ស័យ ប្រតិបត្តិការសាច់ប្រាក់ និងព័ត៌មានស្ដីពីការសង្ស័យនៃសំអាងបទល្មើស ឬការសម្អាតប្រាក់ ឬហិរញ្ញប្បទានភេរវកម្ម
- ប្រមូលព័ត៌មាន និងស្វែងរកព័ត៌មានបន្ថែមដែលទាក់ទងដល់សកម្មភាពស្ដីពីការសម្អាតប្រាក់ ឬហិរញ្ញប្បទានភេរវកម្ម និងព័ត៌មានពាក់ព័ន្ធផ្សេងៗ
- វិភាគ និងវាយតម្លៃនូវរាល់របាយការណ៍ប្រតិបត្តិការសង្ស័យ និងព័ត៌មានពាក់ព័ន្ធផ្សេងៗ
- បញ្ជូនសំណុំរឿងទៅក្រសួង-ស្ថាប័នអនុវត្តច្បាប់ ដើម្បីចាត់វិធានការ
- សហការផ្លាស់ប្ដូរព័ត៌មាន និងមតិយោបល់ទៅភាគីពាក់ព័ន្ធទាំងក្នុងស្រុក និងអន្តរជាតិ
- សហការពង្រឹងយន្តការអនុវត្តច្បាប់ជាមួយក្រសួង-ស្ថាប័នមានសមត្ថកិច្ច
- រៀបចំការវិភាគយុទ្ធសាស្ត្រ និងគំរូសិក្សា (Typologies)
- គ្រប់គ្រងទិន្នន័យ ឯកសារ និងព័ត៌មានពាក់ព័ន្ធផ្សេងៗ
- រៀបចំផែនការ និងតាមដានការងារពាក់ព័ន្ធនឹងការងារវិភាគ
- បំពេញការងារផ្សេងៗ ដែលថ្នាក់ដឹកនាំប្រគល់ជូន។

**មាត្រា៩ .-**

នាយកដ្ឋានត្រួតពិនិត្យការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តកាតព្វកិច្ចប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មរបស់បុគ្គលរាយការណ៍
- វាយតម្លៃហានិភ័យការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មរបស់បុគ្គលរាយការណ៍ និងតាមវិស័យ
- ណែនាំឱ្យបុគ្គលរាយការណ៍ប្រកាន់យកនូវសកម្មភាពកែតម្រូវ
- ពង្រឹងការអនុវត្តច្បាប់ពាក់ព័ន្ធការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- លើកសំណើដាក់ទណ្ឌកម្មបុគ្គលរាយការណ៍ចំពោះការមិនប្រតិបត្តិតាមច្បាប់និងបទប្បញ្ញត្តិស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- រៀបចំផែនការ និងតាមដានការងារពាក់ព័ន្ធនឹងការត្រួតពិនិត្យ
- បំពេញការងារផ្សេងៗ ដែលថ្នាក់ដឹកនាំប្រគល់ជូន។

**មាត្រា១០ .-**

នាយកដ្ឋានសហប្រតិបត្តិការ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- សម្របសម្រួល និងចូលរួមរៀបចំនិងអនុវត្តយន្តការសហប្រតិបត្តិការក្នុងស្រុក និងអន្តរជាតិ
- ទទួលបន្ទុកការងារសហប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធទាំងក្នុងស្រុក និងអន្តរជាតិ
- សម្របសម្រួលការរៀបចំយុទ្ធសាស្ត្រ គោលនយោបាយ និងការវាយតម្លៃហានិភ័យសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- សម្របសម្រួល និងតាមដានវឌ្ឍនភាពនៃការអនុវត្តតាមស្តង់ដាអន្តរជាតិ
- សម្របសម្រួលការងារប្រមូល ឬគ្រប់គ្រង ព័ត៌មាន និងទិន្នន័យ ពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការទូទៅ
- រៀបចំផែនការ និងតាមដានការងារពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការក្នុងស្រុក និងអន្តរជាតិ
- បំពេញការងារផ្សេងៗ ដែលថ្នាក់ដឹកនាំប្រគល់ជូន។

**មាត្រា១១ .-**

នាយកដ្ឋាននីតិកម្មនិងបណ្តុះបណ្តាល មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំ ឬសហការរៀបចំ សេចក្តីណែនាំ ឬលិខិតបទដ្ឋានគតិយុត្តនានា
- សិក្សា និងចងក្រងឯកសារគតិយុត្ត កិច្ចព្រមព្រៀង និងអនុស្សរណៈយោគយល់ ជាដើម
- ផ្តល់មតិយោបល់ទាក់ទងនឹងការអនុវត្តកាតព្វកិច្ចនៃច្បាប់និងបទប្បញ្ញត្តិស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- រៀបចំ និង/ឬសហការផ្សព្វផ្សាយ និងបណ្តុះបណ្តាលដើម្បីលើកកម្ពស់ការយល់ដឹងការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

- សិក្សា និងស្រាវជ្រាវពីការវិវត្តពាក់ព័ន្ធនឹងការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- ប្រមូល ចងក្រង និងរៀបចំឯកសារស្រាវជ្រាវពាក់ព័ន្ធនឹងការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ទាំងក្នុងស្រុកនិងអន្តរជាតិ
- រៀបចំផែនការ និងតាមដានការងារពាក់ព័ន្ធនឹងនីតិកម្មនិងការបណ្តុះបណ្តាល
- បំពេញការងារផ្សេងៗ ដែលថ្នាក់ដឹកនាំប្រគល់ជូន។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា១២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា១៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១៤កើត ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១៣
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១៤៧ អនក្រ.បក ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ២០២០

## រចនាសម្ព័ន្ធរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា



**© ឆ្នាំ២០២០**
មិនអនុញ្ញាតឱ្យផលិតឡើងវិញ ឬបកប្រែសៀវភៅនេះដោយគ្មានការអនុញ្ញាតជាមុនជាលាយលក្ខណ៍អក្សរឡើយ។
ការផលិតឡើងវិញទាំងស្រុង ឬមួយផ្នែកនៃសៀវភៅនេះត្រូវស្នើសុំការអនុញ្ញាតពី:

អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា
**សារអេឡិចត្រូនិច:** cafiu_info@nbc.org.kh
**ទូរស័ព្ទ:** +855 23 427 933
**គេហទំព័រ:** https://www.nbc.org.kh/cafiu/index.html

**© 2020**
No reproduction or translation of this publication may be made without prior written permission.
Applications for permission to reproduce all or part of this publication should be made to:

Cambodia Financial Intelligence Unit
**Email:** cafiu_info@nbc.org.kh
**Tel:** +855 23 427 933
**Website:** https://www.nbc.org.kh/cafiu/index.html

បោះពុម្ពដោយ:
អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា